ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ១៧/០៩ ប.ស.ស

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០០៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះធ្វើអធិការកិច្ចនៅតាមបណ្តាសហគ្រាស ដែលបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម

អនុលោមតាមប្រកាសលេខ ០៨១/០៩ កប/ប្រក ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៩ ស្តីពី ការកំណត់តួនាទី ភារកិច្ច របស់អធិការ និងអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិរបបសន្តិសុខសង្គមសូមជូនដំណឹងដល់លោក/លោកស្រីនាយក ឬម្ចាស់សហគ្រាសទាំងអស់ ដែលបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតអោយបានជ្រាបថា: ដើម្បីធានានូវប្រសិទ្ធិភាពនៃការអនុវត្តន៍ច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ជាជាធរមាននានាដែលទាក់ទងនឹងវិស័យសន្តិសុខសង្គម ប.ស.ស នឹងចាប់ផ្តើមចុះធ្វើអធិការកិច្ចនៅតាមគ្រប់សហគ្រាស គ្រឹះស្ថាន ចាប់ពី ខែកញ្ញា ឆ្នាំ២០០៩តទៅ។

អាស្រ័យដូចបានជម្រាបជូននេះ សូមលោក/លោកស្រីនាយក ឬម្ចាស់សហគ្រាសចូលរួមសហការបង្កលក្ខណៈងាយស្រួល និងត្រៀមនូវឯកសារពាក់ព័ន្ធមួយចំនួនដូចជា: ទម្រង់របាយការណ៍កម្មករនិយោជិត (លេខ ១.០២) បែបបទបង់ប្រាក់ភាគទាន (លេខ ២.០១) សៀវភៅបើកប្រាក់ឈ្នួល ជាដើម។

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក/លោកស្រីនឹងចូលរួមអនុវត្តច្បាប់ជាក់ជាពុំខាន។

នាយក

អ៊ុក.សមវិទ្យា